ឬបង្កអោយមាន ការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អ៊ុត ឆ្រាំង

* * *

## ២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## ប្រកាស

ភ្នំពេញ, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

**ប្រកាសលេខ : ៣២៧ អយក. ប្រក**

**ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យព្រែកអំបិលទៅជា" អនុវិទ្យាល័យ ហ៊ុន សែន — ព្រែកអំបិល" ក្នុងស្រុកស្អាង ខេត្តកណ្តាល**

* * *

**រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា**

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤
- បានឃើញក្រឹត្យ– ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- យោងលិខិតរបស់គណៈទ្រទ្រង់អនុវិទ្យាល័យព្រែកអំបិលលេខ ០១–៩៦ អនុវិ. ព. ប ចុះថ្ងៃទី ១៧ មីនា១៩៩៥ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាលខេត្តកណ្តាល
- តាមសំណើរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

**សម្រេច**

**ប្រការ ១** : អនុញ្ញាតអោយប្តូរឈ្មោះអនុវិទ្យាល័យព្រែកអំបិលបច្ចុប្បន្នទៅជា«អនុវិទ្យាល័យ **ហ៊ុន សែន**– ព្រែកអំបិល » ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ តទៅ ។

**ប្រការ២** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និង កីឡា–ប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្តកណ្តាល និង នាយកអនុវិទ្យាល័យ ហ៊ុន សែន– ព្រែកអំបិល មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
**គា សាឃាន**

* * *

ភ្នំពេញ, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

**ប្រកាសលេខ: ៣២៨ អយក.ប្រក**

**ស្តីពីការបើក អនុវិទ្យាល័យ ហ៊ុន សែន–ត្រប់ ក្នុងស្រុកបាធាយ ខេត្ត កំពង់ចាម**

* * *

**រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា**

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា